ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខ៖ ២៤៥/២២ គ.វ.ក-១៩

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី៣ ឬដូសជំរុញ ជូនដល់កុមារដែលមានអាយុ ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ និងកុមារដែលមានអាយុ ៥ឆ្នាំ ចាប់ផ្តើមពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា គ.វ.ក-១៩ នឹងផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ដោយប្រើប្រាស់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនដល់កុមារ ដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ និងកុមារដែលមានអាយុ ៥ឆ្នាំ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ដូចមានរៀបរាប់ខាងក្រោម៖

### I. ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី៣ ឬដូសជំរុញ ជូនដល់កុមារដែលមានអាយុ ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ

### ក. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនដល់កូនចៅមន្ត្រីរាជការថ្នាក់ជាតិ៖

ចំពោះកូនចៅរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ថ្នាក់ជាតិ ដែលមានអាយុចាប់ពី៦ឆ្នាំ ដល់អាយុក្រោម១២ឆ្នាំ ហើយបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ហើយមានគម្លាតចាប់ពី ៤ខែឡើង សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ នៅតាមមន្ទីរពេទ្យជាតិនានា ដែលមានទីតាំង កាលបរិច្ឆេទ និងពេលវេលាដូចខាងក្រោម៖

### ១. មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះអង្គឌួង៖

- ចំពោះកូនចៅថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំរដ្ឋសភា សមាជិករដ្ឋសភា និងកូនចៅឥស្សរជនដែលមានតួនាទីជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅមន្ទីរពេទ្យកាល់ម៉ែត។
- ចំពោះកូនចៅឥស្សរជនដែលជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅមន្ទីរពេទ្យព្រះអង្គឌួង។

ការចាក់វ៉ាក់សាំងដូសទី៣ឬដូសជំរុញជូនដល់ក្រុមគោលដៅខាងលើ នឹងត្រូវរៀបចំតាមពេលវេលា និងកាលបរិច្ឆេទដូចខាងក្រោម៖

| លរ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ២១ ដល់ ២២ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ទីស្តីការគណៈរដ្ឋមន្ត្រី | | |
| ៥ | -រដ្ឋសភា | | |



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

| | | | |
|---|---|---|---|
| ៦ | -ក្រសួងសុខាភិបាល | ២៣ ដល់ ២៤ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៨ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៩ | -ក្រសួងអប់រំ យុវជន និងកីឡា | | |
| ១០ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ២៥ ដល់ ២៦ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងព័ត៌មាន | | |
| ១២ | -តុលាការកំពូល | | |
| ១៣ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១៤ | -ធនាគារជាតិ នៃកម្ពុជា | | |
| ១៥ | -ក្រសួងមហាផ្ទៃ | ២៧ ដល់ ២៨ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៦ | -ក្រសួងការពារជាតិ | | |
| ១៧ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | |
| ១៨ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ១៩ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០១ ដល់ ០២ មីនា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២០ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ២១ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |
| ២២ | -ក្រសួងផែនការ | | |
| ២៣ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ០៣ ដល់ ០៤ មីនា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៤ | -អាជ្ញាធរសេវាកម្មជាតិ | | |
| ២៥ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| ២៦ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | | |
| ២៧ | -ក្រសួងបរិស្ថាន | | |
| ២៨ | -អង្គភាពប្រឆាំងអំពើពុករលួយ | ០៥ ដល់ ០៧ មីនា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៩ | -ក្រសួងកិច្ចការនារី | | |
| ៣០ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | |
| ៣១ | -ក្រសួងពាណិជ្ជកម្ម | | |
| ៣២ | -ក្រសួងមុខងារសាធារណៈ | | |
| ៣៣ | -កាកបាទក្រហមកម្ពុជា | | |
| ៣៤ | -ក្រសួងទេសចរណ៍ | ០៨ ដល់ ០៩ មីនា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣៥ | -ក្រសួងធម្មការ និងសាសនា | | |
| ៣៦ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ៣៧ | -ក្រសួងធនធានទឹក និងឧតុនិយម | | |
| ៣៨ | -ក្រសួងយុត្តិធម៌ | | |
| ៣៩ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | |
| ៤០ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |
| ៤១ | -ក្រសួងរ៉ែ និងថាមពល | | |



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | | |
|---|---|---|---|
| ៤២ | -អគ្គិសនីកម្ពុជា | ១០ ដល់ ១១ មីនា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៤៣ | -អាជ្ញាធរប្រេងកាត | | |
| ៤៤ | -អាកាសចរស៊ីវិល | | |
| ៤៥ | -អាជ្ញាធរផ្សេងៗ | | |

**២. មន្ទីរពេទ្យកុមារជាតិ៖**

មន្ទីរពេទ្យកុមារជាតិ ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូវ៉ាក់ដូសទី៣ ឬដូសជំរុញ ជូនដល់កូនចៅមន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិនៃក្រសួង-ស្ថាប័នចំនួន១៣ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងសុខាភិបាល | ២១ ដល់ ២៤ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងមហាផ្ទៃ | ២៥ ដល់ ២៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣ | -ក្រសួងការពារជាតិ | ០១ ដល់ ០៣ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៤ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០៤ ដល់ ០៧ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -ធនាគារជាតិ នៃកម្ពុជា | | |
| ៦ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ០៨ ដល់ ១០ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ៨ | -ក្រសួងអប់រំ យុវជន និងកីឡា | ១១ ដល់ ១៤ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -ក្រសួងមុខងារសាធារណៈ | | |
| ១០ | -កាកបាទក្រហមកម្ពុជា | | |
| ១១ | -ក្រសួងយុត្តិធម៌ | ១៥ ដល់ ១៧ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១២ | -ក្រសួងផែនការ | | |
| ១៣ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |

**៣. មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក៖**

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនដល់កូនចៅមន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ មន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ នៃក្រសួង-ស្ថាប័នចំនួន១០ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ២១ ដល់ ២៣ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ក្រុមប្រឹក្សាធម្មនុញ្ញ | ២៤ ដល់ ២៥ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -រដ្ឋសភា | | |
| ៦ | -ទីស្តីការគណៈរដ្ឋមន្ត្រី | ២៦ ដល់ ២៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |

| | | | |
|---|---|---|---|
| ៨ | -តុលាការកំពូល | ០១ ដល់ ០៣ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១០ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | |

### ៤. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនដល់កូនចៅមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ នៃក្រសួង-ស្ថាប័នចំនួន១០ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | ២១ ដល់ ២៤ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងកិច្ចការនារី | | |
| ៣ | -ក្រសួងទេសចរណ៍ | | |
| ៤ | -ក្រសួងព័ត៌មាន | ២៥ ដល់ ២៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -ក្រសួងបរិស្ថាន | | |
| ៦ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ០១ ដល់ ០២ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -អាជ្ញាធរសវនកម្មជាតិ | | |
| ៨ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០៣ ដល់ ០៦ មីនា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -អង្គភាពប្រឆាំងអំពើពុករលួយ | | |
| ១០ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០៧ ដល់ ០៨ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

### ៥. មន្ទីរពេទ្យគន្ធបុប្ផា៖

មន្ទីរពេទ្យគន្ធបុប្ផាជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ និងដូសជំរុញ ជូនដល់កូនចៅមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ នៃក្រសួង-ស្ថាប័នចំនួន១២ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងពាណិជ្ជកម្ម | ២១ ដល់ ២៤ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងធម្មការ និងសាសនា | | |
| ៣ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | |
| ៤ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ២៥ ដល់ ២៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -ក្រសួងធនធានទឹក និងឧតុនិយម | | |
| ៦ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ ដល់ ០៣ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |
| ៨ | -ក្រសួងរ៉ែ និងថាមពល | ០៤ ដល់ ០៦ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -អគ្គិសនីកម្ពុជា | | |
| ១០ | -អាជ្ញាធរប្រេងកាត | ០៧ ដល់ ០៩ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -អាកាសចរស៊ីវិល | | |
| ១២ | -អាជ្ញាធរផ្សេងៗ | ១០ ដល់ ១៣ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## ខ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនដល់កូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិក ស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ អ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា៖

ចំពោះកូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី បុគ្គលិកស្ថានទូត ស្ថានកុងស៊ុល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា មន្ត្រី បុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត កូនចៅសភាពាណិជ្ជកម្ម អ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា សូមទៅទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅ**មន្ទីរពេទ្យកាល់ម៉ែត** តាមពេលវេលា និងកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះអង្គភាព | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -កូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូត ស្ថានកុងស៊ុល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា | ១៤ ដល់ ១៥ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -កូនចៅមន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត | ១៦ ដល់ ១៧ មីនា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣ | -កូនចៅសភាពាណិជ្ជកម្ម អ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា | ១៨ - ២០ ខែមីនា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

## គ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញជូនដល់កូនចៅមន្ត្រីរាជការថ្នាក់ក្រោមជាតិ និងកូនចៅប្រជាពលរដ្ឋទូទៅ៖

យោងតាមកាលបរិច្ឆេទ នៃការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ជូនដល់កុមារមានអាយុចាប់ពី៦ឆ្នាំ ដល់អាយុក្រោម១២ឆ្នាំ ដើម្បីឱ្យមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ គ.រ.ក-១៩ សូមរៀបចំកាលបរិច្ឆេទ នៃយុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ដូសទី៣ ឬដូសជំរុញ ជូនដល់ក្រុមគោលដៅនេះនៅទូទាំង២៥រាជធានី-ខេត្ត ដោយនឹងចាប់ផ្តើមពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ដូចមានក្នុងតារាងខាងក្រោម៖

<table>
<tr><th>ល.រ</th><th>រាជធានី/ខេត្ត</th><th>កាលបរិច្ឆេទបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ</th></tr>
<tr><td>១</td><td>ភ្នំពេញ</td><td rowspan="12">ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២</td></tr>
<tr><td>២</td><td>កណ្តាល</td></tr>
<tr><td>៣</td><td>ព្រះសីហនុ</td></tr>
<tr><td>៤</td><td>កោះកុង</td></tr>
<tr><td>៥</td><td>បាត់ដំបង</td></tr>
<tr><td>៦</td><td>កំពង់ធំ</td></tr>
<tr><td>៧</td><td>ក្រចេះ</td></tr>
<tr><td>៨</td><td>ព្រះវិហារ</td></tr>
<tr><td>៩</td><td>ពោធិ៍សាត់</td></tr>
<tr><td>១០</td><td>រតនគិរី</td></tr>
<tr><td>១១</td><td>ប៉ៃលិន</td></tr>
<tr><td>១២</td><td>ត្បូងឃ្មុំ</td></tr>
<tr><td>១៣</td><td>បន្ទាយមានជ័យ</td><td rowspan="5">ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២</td></tr>
<tr><td>១៤</td><td>កំពង់ចាម</td></tr>
<tr><td>១៥</td><td>កំពង់ឆ្នាំង</td></tr>
<tr><td>១៦</td><td>កំពង់ស្ពឺ</td></tr>
<tr><td>១៧</td><td>កំពត</td></tr>
</table>



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | |
|---|---|---|
| ១៨ | មណ្ឌលគិរី | |
| ១៩ | ព្រៃវែង | |
| ២០ | ស្ទឹងត្រែង | |
| ២១ | ស្វាយរៀង | |
| ២២ | តាកែវ | |
| ២៣ | ឧត្តរមានជ័យ | |
| ២៤ | កែប | |
| ២៥ | សៀមរាប | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ |

ចំពោះកូនចៅមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ព្រមទាំងកូនចៅប្រជាពលរដ្ឋទូទៅ ក្រោមឱវាទ**រដ្ឋបាលរាជធានី-ខេត្តទាំង២៥** ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ នឹងត្រូវរៀបចំចាក់ជូនដោយ**រដ្ឋបាលរាជធានី-ខេត្តទាំង២៥** ដែលរដ្ឋបាលរាជធានី-ខេត្ត នឹងចេញសេចក្តីជូនព័ត៌មានពីទីតាំងនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ផ្សព្វផ្សាយជូនសាធារណជនជ្រាប។

## II. ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី៣ ឬដូសជំរុញ ជូនដល់កុមារដែលមានអាយុ ៥ឆ្នាំ

- ចំពោះកូនចៅមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ថ្នាក់ជាតិ កូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូតនានា មន្ត្រី និងបុគ្គលិក អង្គការជាតិ-អន្តរជាតិ អ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា អាចអញ្ជើញទៅទទួលយកការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅតាមបណ្តា**មន្ទីរពេទ្យជាតិទាំង៦** ដូចជាមន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យព្រះអង្គឌួង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។
- ចំពោះកូនចៅមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ថ្នាក់ក្រោមជាតិ ព្រមទាំងកូនចៅប្រជាពលរដ្ឋទូទៅ **ក្រោមឱវាទរដ្ឋបាលរាជធានី-ខេត្តទាំង២៥** នឹងត្រូវរៀបចំចាក់ជូនដោយ**រដ្ឋបាលរាជធានី-ខេត្តទាំង២៥** ដែលរដ្ឋបាលរាជធានី-ខេត្ត នឹងចេញសេចក្តីជូនព័ត៌មានពីទីតាំង នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ផ្សព្វផ្សាយជូនសាធារណជនជ្រាប។
- ដើម្បីឱ្យមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ គ.វ.ក-១៩ សូមរៀបចំយុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី៣ ឬដូសជំរុញ ជូនដល់ក្រុមគោលដៅនេះ **នៅទូទាំង ២៥រាជធានី-ខេត្ត ដោយចាប់ផ្តើមពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២**។

## III. ឯកសារត្រូវភ្ជាប់ជាមួយនៅពេលទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ៖

ចំពោះគ្រប់កុមារ ដែលមានអាយុចាប់ពី៥ឆ្នាំ ដល់អាយុក្រោម១២ឆ្នាំ ដែលត្រូវទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ត្រូវភ្ជាប់មកជាមួយនូវ ឯកសារមួយចំនួនដូចខាងក្រោម៖

- ប័ណ្ណ (កាត) ចាក់វ៉ាក់សាំងកូវីដ-១៩
- ឯកសារដែលប្រើប្រាស់ក្នុងការចុះឈ្មោះចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១
- និងប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសំគាល់មន្ត្រីជាប់កិច្ចសន្យា របស់ឪពុកម្តាយ (ចំពោះកូនចៅមន្ត្រីរាជការថ្នាក់ជាតិ)។

## IV. កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរមូលដ្ឋាន ៖

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនព័ត៌មានស្តីពីការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនកុមារដែលមានអាយុចាប់ពី៦ឆ្នាំ ដល់អាយុក្រោម១២ឆ្នាំ និងកុមារដែលមានអាយុ ៥ឆ្នាំ ដោយមានភ្ជាប់ជាមួយនូវកម្មវិធី ពេលវេលា និងទីតាំងត្រូវចាក់វ៉ាក់សាំងកូវីដ-១៩

និងត្រូវចាត់ចែងរៀបចំការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់កុមារ ដែលមកចាក់វ៉ាក់សាំងទាំងអស់ឱ្យមានភាពរលូន និងគ្រប់គ្រងសណ្តាប់ធ្នាប់ ព្រមទាំងអនុវត្តនូវវិធានការសុខាភិបាល **ពាក់ម៉ាស់ រក្សាគម្លាតសុវត្ថិភាពចាប់ពី១,៥ម៉ែត្រឡើង លាងដៃញឹកញាប់** ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ លោកអ៊ុំ ពូ មីង ពុក ម៉ែ បងប្អូនទាំងអស់ សូមមេត្តានាំកូនចៅ ចៅទួត ក្មួយៗ ដែលមានអាយុចាប់ពី៦ឆ្នាំ ដល់អាយុក្រោម១២ឆ្នាំ និងអាយុ៥ឆ្នាំ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និង ដូសទី២ រួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅតាមទីតាំង និងកាលបរិច្ឆេទដែលបានកំណត់ឱ្យបានគ្រប់គ្នា។

ទន្ទឹមគ្នានេះដែរ ទោះបីជា បុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចរាល់ហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «***៣ការពារ***» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើងទៅ) និង «***៣កុំ***» (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិក្រោមប្រធានបទ «***រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩***» ដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង ដែលកំពុងចរាចរយ៉ាងសកម្មនាពេលបច្ចុប្បន្ននេះ។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០១២ ៩១៦ ០៩៩ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ ថ្ងៃសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩